**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៦១ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា** (SETHAVITOU Notary Public of the Kingdom of Cambodia)

សរសេរកាត់ជាភាសាខ្មែរ "**ម.ស.ស**" និងសរសេរកាត់ជាភាសាអង់គ្លេស "**S.H Notary Public**" ។

**មាត្រា ២.-**

មន្ទីរសារការី សេដ្ឋារិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅអគារលេខ ៧៣ ផ្លូវលេខ ១២៦ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**មាត្រា ៣.-**

មន្ទីរសារការី សេដ្ឋារិទ្ធ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានា តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតបន្ថែមនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថាសមស្របសម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមមាត្រា ៥ នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោក **នាក់ សេរីគីរិន** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារការី សេដ្ឋាវិទូ

២-លោក **ដាវ អានសាន** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី សេដ្ឋាវិទូ

៣-លោក **ម៉ួន សារៈមុនី** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារការី សេដ្ឋាវិទូ

៤-លោក **ទី ហ្សានិត** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី សេដ្ឋាវិទូ។

ក្នុងករណីចាំបាច់ មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារការីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងយុត្តិធម៌  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា ៥ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ